ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

តុលាការរដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណីលេខ ១៤១
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣
**សាលក្រមលេខ ១២"ក"/១៥៧**
ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី១១ខែឧសភា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ឋានៈ ប្រធានសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជីសាលាដំបូង

**ដើមចោទ៖**

ធនាគារ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប) តំណាងស្របច្បាប់ដោយ លោក [redacted] Chi Jen កាន់លិខិតឆ្លងដែនលេខ ៣០៩២៨៧៥៨៨ ជាអគ្គនាយកធនាគារ ។

អាសយដ្ឋាន៖ ចុះបញ្ជីលេខ២០៥៨៣ ផ្លូវជាតិលេខ៦A [redacted] ។

អ្នកតំណាងដោយអាណត្តិ ៖ មេធាវី [redacted] ,មេធាវី [redacted] និងមេធាវី [redacted] មានការិយាល័យ [redacted] មានអាសយដ្ឋានជាន់ [redacted] ។

**សហចុងចម្លើយ៖**

១-ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស កើតថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៦៣ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: [redacted](១) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ។

២-ឈ្មោះ [redacted] សារ៉ាវ ភេទស្រី កើតថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៣ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: [redacted](១) ។

អាសយដ្ឋាន៖ [redacted] ។

## អំពីអង្គហេតុ និងចំណុចវិវាទ

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖**

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវ សងប្រាក់ឱ្យដើមចោទឈ្មោះ ធនាគារ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប) ដូចខាងក្រោម៖



Scanned with CamScanner

ក. ប្រាក់ដើមដែលនៅជំពាក់ចំនួន  KHR  ៣.០១២.៦៧៣.៥១៣(បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ។

ខ.អត្រាការប្រាក់ចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមដែលនៅជំពាក់ចំនួន KHR ៣.០១២.៦៧៣.៥១៣(បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ ។

គ.អត្រាការប្រាក់មិនអនុវត្តកាតព្វកិច្ចចំនួន ១,៥ ដង នៃអត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ)ស្មើនឹង ១១,៤% (ដប់មួយក្បៀសបួនភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមដែលនៅជំពាក់ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់ ។

ឃ. ការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

២.បង្គាប់ឱ្យសហចុងចម្លើយសងសំណងការខូចខាត,ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ និងសេវាកម្មច្បាប់ឱ្យដើមចោទចំនួន USD ៣៣.៨០០ (សាមសិបបីពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិក)។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៤. សាលក្រមនេះសុំប្រកាសអនុវត្តជាបណ្តោះអាសន្នគ្រប់ចំណុចនៃការទាមទារ ។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ**

**ខ.១.ការសង្ខេបអំពីរឿងក្តី**

កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវ បានចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារ [redacted] (សាខាវងសៀមរាប) ប្រាក់ដើមចំនួន KHR ៣ ១៥០ ០០០ ០០០ (បីពាន់មួយរយហាសិបលានរៀល) អត្រាការប្រាក់ ៧.៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើម រយៈពេលកម្ចី ១៤៤ ខែ គិតចាប់ពីកាលបរិច្ឆេទដកប្រាក់លើកដំបូងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០៣១។ កម្ចីនេះសហចុងចម្លើយមានកាតព្វកិច្ចសងបណ្តាក់ប្រចាំខែនូវប្រាក់ដើម និងការប្រាក់ ឱ្យដើមចោទដោយផ្អែកតាមតារាងបង់រំលស់រយៈពេល ១៤៤ខែ (១២ឆ្នាំ)។ អត្រាការប្រាក់ក្នុងករណីមិនអនុវត្តកាតព្វកិច្ចចំនួន ១,៥ដង នៃអត្រាការប្រាក់ដែលអាចអនុវត្តបានចាប់ពីថ្ងៃ ដែលមានព្រឹត្តិការណ៍មិនអនុវត្តកាតព្វកិច្ចកើតឡើងស្របតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

ដើម្បីធានាដល់ប្រាក់កម្ចីខាងលើ សហចុងម្លើយបានព្រមព្រៀងចុះបញ្ជីបង្កើតហ៊ីប៉ូតែក្សម ដើម្បីធានាបំណុលចំពោះធនាគារនូវអចលនទ្រព្យជាកម្មសិទ្ធិរបស់ខ្លួនចំនួន ០៣ (បី) កន្លែង មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៩០១-០៥៨៨ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ មានទីតាំងស្ថិតនៅភូមិពោធិ៍ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប, វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០១-១១៣៣ ចុះថ្ងៃទី២៧ខែតុលា ឆ្នាំ២០០៨ មានទីតាំងស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និងដីមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-

០៨៨៦ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ មានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប តាមរយៈកិច្ចសន្យាខ្ចីបរិភោគនិងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ។

បំណុលចំនួន KHR ៣១៥០ ០០០ ០០០ (បីពាន់មួយរយហាសិបលានរៀល) សហចុងចម្លើយ បាន អនុវត្តកាតព្វកិច្ចពេញលេញសងបណ្ដាក់ប្រចាំខែនូវ ប្រាក់ដើម និងការប្រាក់ឱ្យដើមចោទ បានចំនួន ១០ ខែ គិតចាប់ពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ តាមតារាងបង់ប្រាក់រយៈពេល ១២ឆ្នាំស្របតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ។ ចាប់ពីពេលនោះមកសហចុងចម្លើយ មិនបានសងប្រាក់ដើមនិងការប្រាក់មកឲ្យដើមចោទទេ ។

**ខ.២.អង្គហេតុដែលគ្មានវិវាទ**

កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវ បាន ចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារ [redacted] (សាខាវងសៀមរាប) ប្រាក់ដើមចំនួន KHR ៣ ១៥០ ០០០ ០០០ (បីពាន់មួយរយហាសិបលានរៀល) អត្រាការប្រាក់ ៧.៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើម រយៈពេលកម្ចី ១៤៤ ខែ គិតចាប់ពីកាលបរិច្ឆេទដកប្រាក់លើកដំបូងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០៣១។ កម្ចីនេះសហចុងចម្លើយមានកាតព្វកិច្ចសងបណ្ដាក់ប្រចាំខែ នូវប្រាក់ដើម និងការប្រាក់ ឱ្យដើមចោទដោយផ្អែកតាមតារាងបង់រំលស់រយៈពេល ១៤៤ខែ (១២ឆ្នាំ)។ អត្រាការប្រាក់ក្នុងករណីមិនអនុវត្តកាតព្វកិច្ចចំនួន ១,៥ដង នៃអត្រាការប្រាក់ដែលអាចអនុវត្តបានចាប់ពីថ្ងៃ ដែល មានព្រឹត្តិការណ៍មិនអនុវត្តកាតួកិច្ចកើតឡើងស្របតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

ដើម្បីធានាដល់ប្រាក់កម្ចីខាងលើ សហចុងម្លើយបានព្រមព្រៀងចុះបញ្ជីបង្កើតហ៊ីប៉ូតែករួម ដើម្បីធានា បំណុលចំពោះធនាគារនូវអចលនទ្រព្យជាកម្មសិទ្ធិរបស់ខ្លួនចំនួន ០៣ (បី) កន្លែង មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៩០១-០៥៨៨ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ មានទីតាំងស្ថិតនៅភូមិពោធិ៍ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប, វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៤០១-១១៣៣ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ មានទីតាំងស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និងដីមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-០៨៨៦ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ មានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប តាមរយៈកិច្ចសន្យាខ្ចីបរិភោគនិងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ។

បំណុលចំនួន KHR ៣១៥០ ០០០ ០០០ (បីពាន់មួយរយហាសិបលានរៀល) សហចុងចម្លើយ បាន អនុវត្តកាតព្វកិច្ចពេញលេញសងបណ្ដាក់ប្រចាំខែនូវ ប្រាក់ដើម និងការប្រាក់ឱ្យដើមចោទ បានចំនួន ១០ ខែ គិតចាប់ពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ តាមតារាងបង់ប្រាក់រយៈពេល ១២ឆ្នាំស្របតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ។ ចាប់ពីពេលនោះមកសហចុងចម្លើយ មិនបានសងប្រាក់ដើមនិងការប្រាក់មកឲ្យដើមចោទទេ ។

សហចុងចម្លើយ បានស្នើសុំដើមចោទ អនុគ្រោះការបង់ប្រាក់ជាបន្តបន្ទាប់ចំនួន ៤(បួន)លើក ហើយ ដើមចោទបានព្រមព្រៀងតាមការស្នើសុំគឺៈ

លើកទី១ សហចុងចម្លើយ សុំបង់តែការប្រាក់សុទ្ធ គិតចាប់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ តាមកិច្ចព្រមព្រៀងកែតំរូវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០។

លើកទី២ សហចុងចម្លើយព្យួរការបង់ការប្រាក់ និងការសងរំលស់ការប្រាក់ គិតចាប់ពីថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ តាមកិច្ចព្រមព្រៀងកែតំរូវ ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២១។

លើកទី៣ សហចុងចម្លើយសុំព្យួរការបង់ការប្រាក់ និងការសងរំលស់ការប្រាក់សំរាប់រយៈពេលនៃកម្ចីរាប់ គិតចាប់ពី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ តាមកិច្ចព្រមព្រៀងកែតំរូវ ចុះ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១។

លើកទី៤ សហចុងចម្លើយ សុំបង់តែការប្រាក់សុទ្ធ គិតចាប់ពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ដល់ថ្ងៃ ទី២៥ ខែមេសា ឆ្នាំ២០២៣ តាមរយៈកិច្ចព្រមព្រៀងកែតំរូវ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ។

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ជាកាលបរិច្ឆេទដែល សហចុងចម្លើយ មានកាតព្វកិច្ចត្រូវ បង់ការ ប្រាក់ប្រចាំខែឱ្យដើមចោទសហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចនោះឡើយ។ ដើមចោទបានដាស់តឿន សហចុងចម្លើយចូលមកអនុវត្តកាតព្វកិច្ចបង់ប្រាក់ តាមរយៈលិខិតដាស់តឿនលេខ ១៤៣/២២ ឃេឌីប៊ី ចុះថ្ងៃ ទី២១ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតដាស់តឿនលើកទី២ លេខ ០១៣/២៣ ឃេឌីប៊ី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ប៉ុន្តែសហចុងចម្លើយ នៅតែមិនអនុវត្តកាតព្វកិច្ចដដែល។

**ខ.៣.ចំណុចវិវាទ**

ដើមចោទទាមទារឲ្យសហចុងចម្លើយសងសំណងការខូចខាត ការខាតបង់ពេលវេលាការចំណាយ ផ្សេងៗ និងសេវាកម្មច្បាប់ឱ្យដើមចោទចំនួន USD ៣៣.៨០០ (សាមសិបបីពាន់ប្រាំបីរយដុល្លារអាមេរិក) សហចុងចម្លើយមិនឯកភាព ដោយការទាមទារនេះមានចំនួនច្រើនហួសហេតុពេក ។

**ខ.៤.ការអះអាងរបស់ភាគី**

**ខ.៤.១.ការអះអាងរបស់ដើមចោទ**

មេធាវី [redacted] អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប) បានធ្វើសេចក្តីថ្លែងការណ៍ថាៈ

- អំពីការទាមទារតាមពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣៖

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវ សងប្រាក់ឱ្យដើមចោទឈ្មោះ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប) ដូចខាងក្រោម៖

ក. ប្រាក់ដើមដែលនៅជំពាក់ចំនួនKHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយ រយចិតសិបបីពាន់ប្រាំរយដប់បីរៀល ) ។

ខ.អត្រាការប្រាក់ចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមដែល នៅជំពាក់ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់ បីរៀល)គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់។

គ.អត្រាការប្រាក់មិនអនុវត្តកាតព្វកិច្ចចំនួន១,៥ដង នៃអត្រាការប្រាក់ចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ)ស្មើនឹង១១,៤ %(ដប់មួយក្បៀសបួនភាគរយ)ក្នុងមួយឆ្នាំនៃប្រាក់ដើមដែលនៅជំពាក់ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់។

ឃ.ការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

២.បង្គាប់ឱ្យសហចុងចម្លើយសងសំណងការខូចខាត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ និងសេវាកម្មច្បាប់ឱ្យដើមចោទចំនួន USD ៣៣.៨០០ (សាមសិបបីពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិក)។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

៤.សាលក្រមនេះសុំប្រកាសអនុវត្តជាបណ្ដោះអាសន្នគ្រប់ចំណុចនៃការទាមទារ ។

ខ្លួនសូមរក្សាសេចក្ដីថ្លែងការណ៍ក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសូមកែប្រែការទាមទារ ចំណុច១.ខ ពីការទាមទារអត្រាការប្រាក់ចំនួន៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមដែលនៅជំពាក់ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល)គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់ ទៅជាអត្រាការប្រាក់ចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមដែល នៅជំពាក់ចំនួន KHR ៣.០១២.៦៧៣-៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល)គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ និងចំណុច១.គ អត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើមដែលនៅជំពាក់ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់ ជំនួសវិញ។

ការទាមទារចំណុចទី១.ក ៖

ដើមចោទទាមទារឲ្យសហចុងចម្លើយសងនូវប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ដោយហេតុថា:

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវបាន ចុះកិច្ចសន្យាខ្ចីបរិភោគជាមួយដើមចោទ [redacted] សាខារងសៀមរាប នូវប្រាក់ដើម ចំនួន KHR ៣.១៥០.០០០.០០០ (បីពាន់មួយរយហាសិបលានរៀល) អត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ)ក្នុងមួយឆ្នាំ ដោយទូទាត់សងប្រាក់ដើម និងការប្រាក់ជារៀងរាល់ខែ សម្រាប់រយៈពេល ១៤២(មួយរយសែសិបពីរ)ខែ ស្មើ១២ឆ្នាំ ។

ដើម្បីជានាដល់ប្រាក់កម្ចីខាងលើ សហចុងចម្លើយបានបង្កើតហ៊ីប៉ូតែក (ប្រាតិភោគ) ជូនដើមចោទនូវអចលនវត្ថុចំនួន០៣កន្លែងគឺ អចលនវត្ថុមានក្បាលដីលេខ៥៨៨ ទីតាំងស្ថិតនៅភូមិពោធិ៍ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ១៧១០០៩០១-០៥៨៨ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប, អចលនវត្ថុមានក្បាលដីលេខ១១៣៣ ទីតាំងស្ថិតនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ១៧១០០៤០១-១១១៣ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប, អចលនវត្ថុមានក្បាលដីលេខ ៨៨៦ ទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ១៧១០០២០៩-០៨៨៦ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប ។

តាមកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ កិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

សហចុងចម្លើយបានសងប្រាក់ដើមមកដើមចោទតាមតារាងបង់ប្រាក់បានរយៈពេល១០ខែ ចាប់ពីពេលនោះមកសហចុងចម្លើយខកខានក្នុងការសងប្រាក់ដើមឲ្យដើមចោទរហូតមកដល់សព្វថ្ងៃ ដែលជាហេតុធ្វើឲ្យសហចុងចម្លើយនៅជំពាក់ប្រាក់ដើមរបស់ដើមចោទ ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ។

ហេតុដូច្នេះហើយទើបដើមចោទទាមទារប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ។

ការទាមទារចំណុចទី១.ខ

ដើមចោទទាមទារឲ្យសហចុងចម្លើយសងអត្រាការប្រាក់ ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣(បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល)គិតចាប់ពីថ្ងៃទី២៥ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២៖

ដោយសារតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ត្រង់ចំណុចប្រការ១ អត្រាការប្រាក់ដើមចោទនិងសហចុងចម្លើយបានព្រមព្រៀងគ្នាក្នុងការកំណត់យកការប្រាក់ចំនួន៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ដែលសហចុងចម្លើយបានខ្ចី ។ តាមបញ្ញត្តិមាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា១៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសលេខ១២៨ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌។ ចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតមកដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ សហចុងចម្លើយមិនបានបង់ការប្រាក់ឲ្យដើមចោទទេ ។

ការទាមទារចំណុចទី១.គ

ដើមចោទទាមទារឲ្យសហចុងចម្លើយសងមកដើមចោទនូវ អត្រាការប្រាក់មិនបំពេញកាតព្វកិច្ចចំនួន

១,៥ ដង នៃអត្រាការប្រាក់ចំនួន៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ស្មើនឹង ១១,៤% (ដប់មួយក្បៀសបួនភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣(បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល)គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់៖

ការទាមទារនេះ ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ត្រង់ចំណុចប្រការ១ ចំណុចអត្រាការប្រាក់(ករណីមិនអនុវត្តកាតព្វកិច្ច) ដើមចោទ និងសហចុងចម្លើយបានព្រមព្រៀងគ្នាកំណត់អនុវត្តយក ១,៥ដង នៃអត្រាការប្រាក់ ៧,៦% ស្មើនឹង ១១,៤% ដោយគិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងគ្រប់ ។ ការទាមទារនេះស្របតាមបញ្ញត្តិមាត្រា ១៧ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រកាសលេខ១២៨ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ត្រង់ប្រការ ២។

ការទាមទារចំណុចទី១.ឃ

**ដើមចោទទាមទារឲ្យសហចុងចម្លើយសងមកដើមចោទនូវ ការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២៖**

ការទាមទារនេះដោយសារកន្លងមក សហចុងចម្លើយបានស្នើសុំដើមចោទ ព្យួរការប្រាក់ និងប្រាក់ដើមក្នុងការសងមកដើមចោទ យោងតាមកិច្ចព្រមព្រៀងកែតម្រូវ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងតាមកិច្ចព្រមព្រៀងកែតម្រូវ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ដោយការប្រាក់បង្គរនេះ សរុបចំនួន KHR ១៩៨.៤២៦.៩៧៩(មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល)គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២១ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរ ថ្ងៃទី១០ខែមករា ឆ្នាំ២០២២ និងដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ។ គឺសហចុងចម្លើយមិនបានបង់ការប្រាក់ គឺដើមចោទយកប្រាក់ដើមដែលនៅជំពាក់គុណនឹងអាត្រាការប្រាក់ក្នុងកិច្ចសន្យាចំនួន ៧,៦% ក្នុងមួយឆ្នាំ គុណនឹងរយៈពេលដែលបានព្យួរ ។ ដោយសារសហចុងចម្លើយបានសងការប្រាក់ព្យួរបានចំនួន៥ដង ដូចនេះសហចុងចម្លើយនៅជំពាក់ការប្រាក់ព្យួរសរុបចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល)។

ការទាមទារចំណុចទី២

**ដើមចោទទាមទារឲ្យសហចុងចម្លើយសងសំណងការខូចខាត ការខាតបង់ពេលវេលាការចំណាយផ្សេងៗនិងសេវាកម្មច្បាប់ឱ្យដើមចោទចំនួន USD ៣៣.៨០០(សាមសិបបីពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិក) ៖**

ការទាមទារនេះ ដោយសារសហចុងចម្លើយបំពានមកលើដើមចោទ និងប៉ះពាល់និរន្តរភាពរបស់ដើមចោទយ៉ាងធ្ងន់ធ្ងរ ។ ការទាមទារនេះយោងតាមមាត្រា ៣៩៨ ,មាត្រា៤០០ ,មាត្រា៤០១ និងមាត្រា

៤០៨ នៃក្រមរដ្ឋប្បវេណី ។

ការទាមទារចំណុចទី៣

ដើមចោទទាមទារឲ្យប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

ការស្នើសុំនេះ ដោយសារសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ច ធ្វើឲ្យប៉ះពាល់ប្រយោជន៍របស់ដើមចោទយោងតាមមាត្រា៦៤ និងមាត្រា៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ការទាមទារចំណុចទី៤

សុំអោយតុលាការប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្ន លើគ្រប់ចំណុចនៃការទាមទាររបស់ដើមចោទ ដោយហេតុថា ដើមចោទមានការព្រួយបារម្ភខ្លាចភាគីសហចុងចម្លើយយកទ្រព្យដែលដាក់បង្កើតហ៊ីប៉ូតែក ទៅចាត់ចែងឲ្យម្ចាស់បំណុលផ្សេងទៀត ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់ភាគីដើមចោទ ដោយយោងតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ខ.៤.២.ការអះអាងរបស់សហចុងចម្លើយ**

សហចុងចម្លើយឈ្មោះ [redacted] សាក់រ៉ា បានធ្វើសេចក្ដីថ្លែងការណ៍ថា៖

ការទាមទារចំណុចទី១.ក

ខ្លួនទទួលស្គាល់ អង្គហេតុថាពិតជាមានការខ្ចីប្រាក់ដូចខាងភាគីដើមចោទលើកឡើងពិតប្រាកដមែន និងទទួលស្គាល់ថានៅជំពាក់ប្រាក់ដើម របស់ធនាគារ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប)ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល)ប្រាកដមែន។ នៅពេលនេះ ខ្លួនពុំទាន់មានលទ្ធភាពសងប្រាក់ទាំងអស់ទៅធនាគារ តាមការទាមទារនេះទេ ។

ការទាមទារចំណុចទី១.ខ ៖

ដើមចោទទាមទារឲ្យសហចុងចម្លើយសងអត្រាការប្រាក់ ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបី ពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ ៖

ខ្លួនពិតជាបានចុះកិច្ចសន្យាលើការប្រាក់ចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមប្រាកដមែន។ ខ្លួនទទួលស្គាល់ថាការទាមទារចំណុចទី១.ខ នេះ លើការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនពិតជាពុំទាន់សងការប្រាក់ឲ្យដើមចោទតាមការទាមទារពិតមែន ។

ការទាមទារចំណុចទី១.គ

ដើមចោទទាមទារឲ្យសហចុងចម្លើយសងមកដើមចោទនូវ អត្រាការប្រាក់មិនបំពេញកាតព្វកិច្ច

ចំនួន១,៥ដង នៃអត្រាការប្រាក់ចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ)ស្មើនឹង ១១,៤% (ដប់មួយក្បៀសបួនភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់៖

ខ្លួនទទួលស្គាល់ការទាមទារចំណុច១.គ លើអត្រាការប្រាក់មិនអនុវត្តកាតព្វកិច្ច ១,៥ដង ស្មើនឹង ១១,៤% លើប្រាក់ដើមដែលនៅជំពាក់ខាងលើ ដោយសារចំណុចនេះមានចែងក្នុងកិច្ចសន្យាដែរ ។

ការទាមទារចំណុចទី១.ឃ

ដើមចោទទាមទារឲ្យសហចុងចម្លើយសងមកដើមចោទនូវ ការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២៖

ខ្លួនទទួលស្គាល់ការទាមទារចំណុច១.ឃ លើការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ដោយសារខ្លួនបានសុំកែតម្រូវកិច្ចសន្យាចំនួន ៤ដង ដូចសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឲ្យដើមចោទពិតប្រាកដមែន ។

ការទាមទារចំណុចទី២

ដើមចោទទាមទារឲ្យសហចុងចម្លើយសងសំណងការខូចខាត ការខាតបង់ពេលវេលាការចំណាយផ្សេងៗ និងសេវាកម្មច្បាប់ឱ្យដើមចោទចំនួន USD ៣៣.៨០០(សាមសិបបីពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិក) ៖

ខ្លួនមិនទទួលស្គាល់ការទាមទាររបស់ដើមចោទត្រង់ចំណុច២ នេះទេ ដោយសារការទាមទារនេះមានចំនួនច្រើនហួសហេតុពេក ។

ការទាមទារចំណុចទី៣

ដើមចោទទាមទារឲ្យប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ

ខ្លួនទទួលស្គាល់ និងយល់ព្រម ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដីនេះ ។

ការទាមទារចំណុចទី៤

ដើមចោទទាមទារសុំឲ្យតុលាការប្រកាសថាសាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្នលើគ្រប់ចំណុចនៃ ការទាមទាររបស់ដើមចោទ៖

ខ្លួនឯកភាពឲ្យតុលាការចេញសាលក្រមមានអានុភាពអនុវត្តជាបណ្ដោះអាសន្ន ។

សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា ក្រឡាបញ្ជីបានបញ្ជូនដីកាកោះត្រឹមត្រូវតាមនីតិវិធីរួចហើយ

ដោយផ្ញើការបញ្ជូនដីកាកោះនិងសេចក្តីថ្លែងការណ៍របស់ដើមចោទឲ្យដល់សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា រួចរាល់ មានឈ្មោះ [redacted] សារ៉ាវ ជាប្រពន្ធជាអ្នកទទួលដីកាកោះ ហើយឈ្មោះនេះបានបញ្ជាក់ថា បានជូនដំណឹងអំពីដីកាកោះធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដល់សហចុងចម្លើយ ប៉ុន្តែនៅពេល ធ្វើនីតិវិធីសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា នៅតែអវត្តមាន។

## ការសំអាងហេតុ

ពាក្យបណ្តឹងអង្គសេចក្តី ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ របស់ធនាគារ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប) តំណាងស្របច្បាប់ដោយ លោក [redacted] Jen កាន់លិខិតឆ្លងដែនលេខ ៣០៩២៨៧៥៨៨ ជាអគ្គនាយកធនាគារ និងមានអ្នកតំណាងដោយអាណត្តិមេធាវី [redacted] និងមេធាវី [redacted] ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១៤១ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ តុលាការអាចលើកយកមកធ្វើការទាញហេតុដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា៩ និងមាត្រា២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាមសេចក្តីថ្លែងការណ៍របស់មេធាវី [redacted] និងសេចក្តីថ្លែងការណ៍របស់ភាគីសហចុងចម្លើយឈ្មោះ [redacted] សារ៉ាវ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យកស្តុតាង ជាឯកសារដែលមានក្នុងសំណុំរឿង ឃើញថា៖

### ក.ការវិនិច្ឆ័យចំពោះចំណុចវិវាទ

ចំណុចវិវាទៈ ដើមចោទទាមទារឲ្យសហចុងចម្លើយសងសងសំណងការខូចខាត ការខាតបង់ពេលវេលាការចំណាយផ្សេងៗនិងសេវាកម្មច្បាប់ឱ្យដើមចោទចំនួន USD ៣៣.៨០០(សាមសិបបីពាន់ប្រាំបីរយដុល្លារអាមេរិក) សហចុងចម្លើយមិនឯកភាព ដោយការទាមទារនេះមានចំនួនច្រើនហួសហេតុពេក ។

យោងតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី និងយោងលិខិតដាស់តឿនលើកទី១ លេខ ១៤៣/២២ យេឌីប៊ី ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតដាស់តឿនលើកទី២ លេខ ០១៣/២៣ យេឌីប៊ី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ តុលាការទទួលស្គាល់ថា សហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចក្នុងការសងប្រាក់ទៅឲ្យដើមចោទ ដែលនេះជាកំហុសរបស់សហចុងចម្លើយ ហេតុនេះសហចុងចម្លើយ មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅឲ្យដើមចោទនេះទេ ។

### ខ.ការវិនិច្ឆ័យចំពោះការទាមទារ

**ខ**.១. ដើមចោទបានប្តឹងទាមទារឱ្យសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវ សងប្រាក់ឱ្យដើមចោទឈ្មោះធនាគារ [redacted] សាខាភ្នំពេញ (សាខារងសៀមរាប)នូវប្រាក់ដើម ការប្រាក់ ការប្រាក់ពិន័យ និងការប្រាក់ដែលព្យួរក្នុងអំឡុងពេល ដូចខាងក្រោម៖

**ខ**.១.ក. ប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល)៖

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឃើញថា ដើមចោទដែលជាអ្នកឲ្យខ្ចីពិតជាបានប្រគល់ប្រាក់ទៅឲ្យសហចុងចម្លើយដែលជាអ្នកខ្ចី ដែលមានទឹកប្រាក់ចំនួន KHR ៣១៥០-000 000 (បីពាន់មួយរយហាសិបលានរៀល)។ តាំងពីខ្ចីមកសហចុងចម្លើយបានសងប្រាក់ដើមមកដើមចោទ តាមតារាងបង់ប្រាក់បានរយៈពេល១០ខែ ចាប់ពីពេលនោះមកសហចុងចម្លើយខកខានឈប់សងប្រាក់ដើមឲ្យដើមចោទរហូតមកដល់សព្វថ្ងៃនេះ ដែលជាហេតុធ្វើឲ្យសហចុងចម្លើយនៅជំពាក់ប្រាក់

ដើមរបស់ដើមចោទចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ។ ចំនួនប្រាក់ដើមខាងលើនេះ សហចុងចម្លើយបានទទួលស្គាល់ថា នៅជំពាក់ចំនួនដូចដើមចោទទាមទារផងដែរ ។

តុលាការទទួលស្គាល់ការខ្ចីបរិភោគរវាងដើមចោទ និងសហចុងចម្លើយធ្វើឡើងមានលក្ខណៈត្រឹមត្រូវស្របតាមមាត្រា ៥៧៨ និងមាត្រា៥៧៩ នៃក្រមរដ្ឋប្បវេណី ។ ចំពោះការទាមទាររបស់ដើមចោទមុនកាលបរិច្ឆេទនៃកិច្ចសន្យាខ្ចីបរិភោគខាងលើ ធ្វើឡើងត្រឹមត្រូវស្របតាមប្រការ ៧ នៃកិច្ចសន្យាខ្ចីបរិភោគ នេះគឺគូភាគីបានព្រមព្រៀងផ្តិតមេដៃ ឬ ចុះហត្ថលេខាទាក់ទងនឹងការមិនបំពេញកាតព្វកិច្ច ។ មួយវិញទៀតផ្អែកលើលិខិតដាស់តឿនលើកទី១ លេខ ១៤៣/២២ យេឌីប៊ី ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតដាស់តឿនលើកទី២ លេខ ០១៣/២៣ យេឌីប៊ី ចុះថ្ងៃទី១០ខែមករា ឆ្នាំ២០២៣ ឃើញថាដើមចោទ បានដាស់តឿនឲ្យសហចុងចម្លើយសងប្រាក់ដើម និងការប្រាក់ជាច្រើនលើកច្រើនសារ តែសហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគខាងលើឡើយ។ ហើយការទាមទាររបស់ដើមចោទក៏ធ្វើឡើងមានលក្ខណៈត្រឹមត្រូវស្របតាមមាត្រា ៣៣១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ។

ដូចនេះ គប្បីតុលាការបង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ទៅឲ្យដើមចោទ ។

**ខ.១.ខ.** ការប្រាក់ក្នុងអត្រាចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ ៖

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ប្រការ១ ចំណុចការប្រាក់ និងផ្អែកតាមកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ចំណុច ២(៣) ដើមចោទ និងសហចុងចម្លើយពិតជាបានផ្តិតមេដៃ និងចុះហត្ថលេខាព្រមព្រៀងគ្នាលើអត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ ប្រាកដមែន ។ ហើយការប្រាក់នេះសហចុងចម្លើយក៏បានទទួលស្គាល់ដែរ ។

ការព្រមព្រៀងលើអត្រាការប្រាក់របស់ដើមចោទ និងសហចុងចម្លើយធ្វើឡើងត្រឹមត្រូវស្របតាមមាត្រា៥៨៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី, មាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រការ១ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក /១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ ទីស្តីការក្រសួងយុត្តិធម៌ ។

ដូចនេះ គប្បីតុលាការសម្រេចបង្គាប់ឲ្យសហចុងចម្លើយសងមកដើមចោទ នូវការប្រាក់ក្នុងអត្រាចំនួន ៧,៦% (ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ ។

**ខ.១.គ.** អត្រាការប្រាក់មិនបំពេញកាតព្វកិច្ច ចំនួន ១,៥ដង នៃអត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ) ស្មើនឹង ១១,៤% (ដប់មួយក្បៀសបួនភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី

២៦ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់ ៖

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ត្រង់ចំណុចប្រការ១ ចំណុចអត្រាការប្រាក់(ករណីមិនអនុវត្តកាតព្វកិច្ច) ដើមចោទ និងសហចុងចម្លើយបានព្រមព្រៀងគ្នាកំណត់អនុវត្តយក ១,៥ដង នៃអត្រាការប្រាក់ ៧,៦% ស្មើនឹង ១១,៤% ក្នុង១ ឆ្នាំ នៃប្រាក់ដើមដែលសហចុងចម្លើយនៅជំពាក់ដើមចោទ ។

តុលាការទទួលស្គាល់ថាដើមចោទ និងសហចុងចម្លើយពិតជាបានព្រមព្រៀងគ្នាជាលិខិតលាយលក្ខណ៍អក្សរមានផ្តិតមេដៃ និងហត្ថលេខារបស់អ្នកខ្ចីកំណត់ជាមុន លើអត្រាការប្រាក់យឺតយ៉ាវ (ប្រាក់ពិន័យ) ចំនួន ១១,៤%(ម្ភៃប្រាំភាគរយ) ក្នុងមួយឆ្នាំ ធ្វើឡើងត្រឹមត្រូវស្របតាម មាត្រា៥៨៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី មាត្រា១៧ កថាខណ្ឌ៣ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រការ ២ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌។ មួយវិញទៀតផ្អែកតាមលិខិតដាស់តឿនលើកទី១លេខ១៤៣/២២ យេឌីប៊ី ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតដាស់តឿនលើកទី២ លេខ០១៣/២៣ យេ ឌី ប៊ី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ របស់ដើមចោទ គឺបានទាមទារឲ្យសហចុងចម្លើយទូទាត់សងប្រាក់ដើម និងការប្រាក់ដែលបាននឹងកំពុងហួសកាលកំណត់ទូទាត់ ចាប់តាំងពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ។

តុលាការទទួលស្គាល់ថា សហចុងចម្លើយពិតជា មិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគឡើយ ហេតុនេះ ដើមចោទអាចទាមទារសំណងនៃអត្រាការប្រាក់យឺតយ៉ាវ (ប្រាក់ពិន័យ) ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន ស្របតាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី ។

ហេតុដូចនេះ គប្បីតុលាការសម្រេចបង្គាប់ឲ្យសហចុងចម្លើយសងមកដើមចោទនូវអត្រាការប្រាក់យឺតយ៉ាវ(ប្រាក់ពិន័យ)ក្នុងអត្រាចំនួន ១១,៤%(ម្ភៃប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់ ។

**ខ**.១.ឃ. ការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ខែមេសា ឆ្នាំ២០២២៖

ការទាមទារនេះដោយសារកន្លងមក សហចុងចម្លើយបានស្នើសុំដើមចោទ ព្យួរការប្រាក់ និងប្រាក់ដើមក្នុងការសងមកដើមចោទ យោងតាមកិច្ចព្រមព្រៀងកែតម្រូវទៅលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងតាមកិច្ចព្រមព្រៀងកែតម្រូវទៅលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២១ ដោយការប្រាក់បង្គរនេះ សរុបចំនួន ១៩៨.៤២៦.៩៧៩(មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល)គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងដល់ថ្ងៃទី២៥ ខែមេសា



Scanned with CamScanner

ឆ្នាំ២០២២ ។ ក្នុងអំឡុងពេលព្យួរសហចុងចម្លើយមិនបានបង់ការប្រាក់ឲ្យដើមចោទទេ ក្នុងការគណនាគឺដើមចោទយកប្រាក់ដើមដែលនៅជំពាក់គុណនឹងអាត្រាការប្រាក់ក្នុងកិច្ចសន្យាចំនួន ៧,៦% ក្នុងមួយឆ្នាំគុណនឹងរយៈពេលដែលបានព្យួរ ។ ដូចនេះសហចុងចម្លើយនៅជំពាក់ការប្រាក់ព្យួរសរុបចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល)។ ការទាមទារនេះសហចុងចម្លើយក៏បានទទួលស្គាល់ការទាមទារនេះដែរ ។

ដូចនេះ តុលាការគប្បីសម្រេចឲ្យសហចុងចម្លើយសងការប្រាក់ព្យួរដែលជំពាក់ គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ទៅឲ្យដើមចោទចំនួន KHR១៩៨.៤២៦.៩៧៩(មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) ។

**ខ.២.ដើមចោទទាមទារឲ្យសហចុងចម្លើយសងប្រាក់ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងចំណាយផ្សេងៗ លើនីតិវិធីដែលមានចំនួនសរុប USD ៣៣.៨០០ (សាមសិបបីពាន់ប្រាំបីរយដុល្លារសហរដ្ឋអាមេរិក)ឲ្យមកដើមចោទ ៖**

យោងតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី និងយោងលិខិតដាស់តឿនលើកទី១ លេខ ១៤៣/២២ យេ ឌីប៊ី ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតដាស់តឿនលើកទី២ លេខ ០១៣/២៣ យេឌីប៊ី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ របស់ដើមចោទ តុលាការទទួលស្គាល់ថា សហចុងចម្លើយមិនអនុវត្តកាតព្វកិច្ច ក្នុងការសងប្រាក់ទៅឲ្យដើមចោទ ដែលនេះជាកំហុសរបស់សហចុងចម្លើយ ហេតុនេះសហចុងចម្លើយមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅឲ្យដើមចោទនេះទេ ។ ដូចនេះ គប្បីតុលាការ សម្រេចឲ្យសហចុងចម្លើយសងសំណងការខូចខាតទៅឲ្យដើមចោទ ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច ទំហំនៃការខូចខាត និងជីវភាពរបស់សហចុងចម្លើយ ស្របតាមមាត្រា ៤០០ និងមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី។

**ខ.៣.សុំឲ្យតុលាការប្រកាសថាសាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្នបាន៖**

ដើមចោទទាមទារសុំឲ្យតុលាការចេញសាលក្រមមានអានុភាពអនុវត្តជាបណ្ដោះអាសន្ន តុលាការពិនិត្យឃើញថា ការប្រកាសសាលក្រមឲ្យអនុវត្តជាបណ្ដោះអាសន្ន ជាការចាំបាច់ចំពោះការទាមទារដែលមានសិទ្ធិលើទ្រព្យសម្បត្តិប៉ុណ្ណោះ ។ តាមខ្លឹមសារនៃការទាមទាររបស់ដើមចោទ ឃើញថា មានតែចំណុចទាមទារទី១.ក ប៉ុណ្ណោះដែលមានលក្ខណៈត្រឹមត្រូវ ហើយចំណុចនៃការទាមទារនេះសហចុងចម្លើយក៏ទទួលស្គាល់ផងដែរ និងយោងតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ គប្បីតុលាការលើកយកមកពិចារណាតាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដោយឡែកការទាមទារឲ្យតុលាការចេញសាលក្រមប្រកាសឲ្យអនុវត្តបណ្ដោះអាសន្ន លើចំណុចផ្សេងទៀតនោះ តុលាការយល់ឃើញថា យោងតាមមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី សេចក្ដីសម្រេចដែលប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន គឺមានអានុភាពយកទៅអនុវត្តដូចជា



Scanned with CamScanner

សាលក្រម ឬសាលដីកាស្ថាពរដែរ ដូចនេះ ក្នុងការសម្រេចសេចក្តីដែលភ្ជាប់នឹងការប្រកាស ឲ្យអនុវត្តជាបណ្តោះអាសន្ននោះត្រូវតែពិចារណាឲ្យបានហ្មត់ចត់បំផុត ។ ម្យ៉ាងទៀតក្នុងករណីមានបណ្តឹងឧបាស្រ័យចំពោះសេចក្តីសម្រេចនៅក្នុងសាលក្រមទៅតុលាការជាន់ខ្ពស់នោះ អាចនឹងមានការផ្លាស់ប្តូរនៅត្រង់ចំណុចណាមួយក្នុងសេចក្តីឲ្យអនុវត្តជាបណ្តោះអាសន្ន ជាហេតុធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីទាំងសងខាង ដូចនេះតុលាការគប្បីសម្រេចច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចទី១.ខ ,១.គ,១.ឃ ចំណុចទី២ និងចំណុចទី៣ នៃការទាមទារក្នុងកម្មវត្ថុបណ្តឹងរបស់ដើមចោទ ។

**គ.បន្ទុកនៃប្រាក់ប្រដាប់ក្តី**

ផ្អែកតាមសំអាងហេតុខាងលើ និងយោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់ភាគីចាញ់ក្តី ហេតុដូចនេះគប្បីតុលាការសម្រេចឲ្យភាគីដែលចាញ់ក្តីជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីនេះ ។

សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា ក្រឡាបញ្ជីបានបញ្ជូនដីកាកោះត្រឹមត្រូវតាមនីតិវិធីរួចហើយ ដោយធ្វើការបញ្ជូននូវដីកាកោះ រួមនិងសេចក្តីថ្លែងការណ៍របស់ដើមចោទ ឲ្យដល់សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា រួចរាល់ដោយឈ្មោះ [redacted] សារ៉ាវ ជាអ្នកទទួលដីកាកោះ ហើយឈ្មោះនេះបានបញ្ជាក់ថាបានជូនដំណឹងអំពីដីកាកោះធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដល់សហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា ប៉ុន្តែសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា នៅតែអវត្តមាន ។ ម្យ៉ាងទៀតនៅពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ សហចុងចម្លើយឈ្មោះ [redacted] សារ៉ាវ បានបញ្ជាក់ថាសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា បានដឹងពីការធ្វើនីតិវិធីនេះហើយ, គាត់នៅតែមិនបានចូលរួម។ ដូចនេះតុលាការចាត់ទុកថាសហចុងចម្លើយដែលអវត្តមានបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលទាក់ទង នឹងអង្គហេតុ ដែលគប្បីសម្រេចទទួលស្គាល់តាមការទាមទាររបស់ដើមចោទស្របតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សេចក្តីសម្រេចបញ្ចប់**

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សារ៉ាវ សងប្រាក់ឱ្យដើមចោទឈ្មោះ ធនាគារ [redacted] សាខាភ្នំពេញ (សាខាវង់សៀមរាប) ដូចខាងក្រោម៖

ក.ប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) ។

ខ.អត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។

គ.អត្រាការប្រាក់មិនអនុវត្តកាតព្វកិច្ចចំនួន ១,៥ ដង នៃអត្រាការប្រាក់ចំនួន ៧,៦%(ប្រាំពីរក្បៀសប្រាំមួយភាគរយ)ស្មើនឹង១១,៤%(ដប់មួយក្បៀសបួនភាគរយ)ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន KHR ៣.០១២.៦៧៣.៥១៣ (បីពាន់ដប់ពីរលានប្រាំមួយរយចិតសិបបីពាន់ប្រាំរយដប់បីរៀល) គិតចាប់ពី



Scanned with CamScanner

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់ ។

ឃ.ការប្រាក់ព្យួរដែលជំពាក់ចំនួន KHR ១៩៨.៤២៦.៩៧៩ (មួយរយកៅសិបប្រាំបីលានបួនរយម្ភៃប្រាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនរៀល) គិតចាប់ពីអំឡុងពេលព្យួរថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងអំឡុងពេលព្យួរថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

២.បង្គាប់ឱ្យសហចុងចម្លើយសងសំណងការខូចខាត ,ការខាតបង់ពេលវេលា ការចំណាយផ្សេង ៗ និងសេវាកម្មច្បាប់ឱ្យដើមចោទ ចំនួន KHR ២០ .០០០.០០០ (ម្ភៃលានរៀល)។

៣.សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុចទី១.ក ។ ច្រានចោលការទាមទារប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១.ខ,ទី១.គ,ទី១.ឃ ,ចំណុចទី២ និងចំណុចទី៣ នៃការទាមទារក្នុងកម្មវត្ថុបណ្តឹងរបស់ដើមចោទ ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ។

ក្នុងករណីដែលប្តឹងឧទ្ធរ ណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី

ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner